ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២០២/១៤ - មិន គួន ចិចថាយ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រ៉ូចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេង ថុង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន មិន គួន ចិចថាយ**

អាសយដ្ឋាន ៖ ភូមិព្រៃសាលា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៧៧ ៤៣០ ៤៩០ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

- លោក គីម សុវណ្ណារិទ្ធ រដ្ឋបាល

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី ២ ៖

- លោក គីម សុវណ្ណារិទ្ធ រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពការងារដើម្បីកម្ពុជា**

- **សហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន មីន គួន**

អាសយដ្ឋាន ៖ ភូមិព្រៃសាលា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៩ ៨១ ៨១ ៥២ ទូរសារ ៖ គ្មាន



58

តំណាងកម្មករនិយោជិត ៖

១- លោក សាន់ ផាន អគ្គលេខាធិការរងសហព័ន្ធសហជីពការងារដើម្បីកម្ពុជា

២- លោក សន សុភាព មន្ត្រីសហព័ន្ធសហជីពការងារដើម្បីកម្ពុជា

៣- កញ្ញា ង៉ែត សុភា អនុប្រធានសហជីពមូលដ្ឋាន

៤- កញ្ញា យុត មើ លេខាធិការសហជីពមូលដ្ឋាន

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី ២ ៖

១- លោក សាន់ ផាន អគ្គលេខាធិការរងសហព័ន្ធសហជីពការងារដើម្បីកម្ពុជា

២- លោក ស៊ឹម សាវុធ មន្ត្រីសហព័ន្ធសហជីពការងារដើម្បីកម្ពុជា

៣- កញ្ញា ង៉ែត សុភា អនុប្រធានសហជីពមូលដ្ឋាន

៤- កញ្ញា យុត មើ លេខាធិការសហជីពមូលដ្ឋាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោល ១០០ ភាគរយ ពេញ ជូនកម្មករនិយោជិត នៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ ហើយឱ្យកម្មករនិយោជិតឈប់សម្រាក។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ឈប់ពីមួយថ្ងៃ ទៅបីថ្ងៃ (ក្រុមហ៊ុនអនុវត្តគោលការណ៍ចាស់ វ៉ៃប៉ុង ហើយត្រឡប់ទៅផ្ទះ ក្រុមហ៊ុនឱ្យ ៥០ % វ៉ៃប៉ុងហើយ ធ្វើការដល់ម៉ោង ០៩៖០០ ព្រឹក ផ្តល់ប្រាក់ឈ្នួលឱ្យ ១០០ ភាគរយ) ។ ចាប់ពីមួយខែ ក្រុមហ៊ុនសុំព្យួរការងារ។

២- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់លុយថ្លៃស្នាក់នៅ ឬថ្លៃធ្វើដំណើរ ចំនួន ១៥ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនគ្មានលទ្ធភាពផ្តល់ជូនឡើយ ក្រុមហ៊ុនផ្តល់ជូនតាមច្បាប់ គឺ ៧ ដុល្លារ។

៣- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនសាងសង់ទារកដ្ឋាន ហើយបើក្រុមហ៊ុនពុំមានលទ្ធភាពសាងសង់ទារកដ្ឋាននោះទេ សុំឱ្យក្រុមហ៊ុនចេញថ្លៃផ្ញើក្មេងនៅទារកដ្ឋានខាងក្រៅ ចំនួន ៤០ ដុល្លារ ក្នុងមួយខែ សម្រាប់ស្ត្រីដែលមានកូនតូចៗ ចាប់ពីអាយុ ១៨ ខែ រហូតដល់អាយុ ៣ ឆ្នាំ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមានលទ្ធភាពផ្តល់ជូនតែ ៥ ដុល្លារ បន្ថែមពីលើ ៥ ដុល្លារ ដែលមានស្រាប់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សា

អាជ្ញាកណ្តាលលេខ ១៣០ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ (អាណត្តិទី១៤)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៨០៦ កប/អក/វក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៤។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ ៖** - ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។

- ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងតាមទូរស័ព្ទរបស់កម្មករនិយោជិតនៃក្រុមហ៊ុន មិន គួន ស្តីពីការធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនដោះស្រាយលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរជូនកម្មករនិយោជិត។ បន្ទាប់ពីបានទទួលបណ្តឹងនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញចុះទៅកាន់ទីតាំងក្រុមហ៊ុន ដើម្បីធ្វើការដោះស្រាយ និងផ្សះផ្សាវិវាទការងាររួមនេះ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៤ ចំណុច និងមិនសះជានឹងគ្នាចំនួន ០៣ ចំណុច លើការទាមទារចំនួន ០៧ ចំណុច។ ចំណុចមិនសះជាចំនួន ០៣ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន មិន គួន លេខ ៨០៦ ក.ប/អក/វក. ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំង ០៣ ចំណុច នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានមកចូលរួម តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំងនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០៣ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ចំណុច គឺចំណុចវិវាទទី០១ និងទី០៣។ ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាទៅលើចំណុចវិវាទមិនសះជាដែលនៅសល់ចំនួន ០១ ចំណុចប៉ុណ្ណោះ គឺ ចំណុចវិវាទទី២។

សេចក្តីបង្គាប់នៅក្នុងសំណុំរឿងនេះ ជាប្រភេទសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារពេលចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ទៅថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៤។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទដែលនៅសល់ខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិត ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ របស់នាយកក្រុមហ៊ុន មីន គួន ធិចថាយ ផ្ទេរសិទ្ធិជូនលោក គីម សុវណ្ណារិទ្ធ។

២- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន មិន គួន ធិចថាយ បានឃើញ និងបញ្ជាក់ថា ត្រឹមត្រូវដោយនាយកដ្ឋានអធិការកិច្ចការងារ លេខ ០៣៩ សកបយ.អក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤។

៣- លិខិតលេខ ៦៩២ ពណ.នគក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បញ្ជាក់ថា ក្រុមហ៊ុន មិន គួន ធិចថាយ ជាក្រុមហ៊ុនវិនិយោគទុនឯកជនមួយ ត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៤- វិញ្ញាបនបត្រលេខ ៤១៧៩ ពណ.ចបព ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន មិន គួន ធិចថាយ។

៥- កំណត់ហេតុស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន មិន គួន ធិចថាយ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

៦- លក្ខន្តិកៈក្រុមហ៊ុន មិន គួន ធិចថាយ តំកល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មលេខ ៥០២/០៤ ពណ.ចកព ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧។

៧- កិច្ចប្រជុំស្តីពីការឯកភាពផ្តល់ និងទទួលប្រាក់ថ្លៃបាយថ្ងៃត្រង់ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៤។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន មីន គួន លេខ ០៣៣/១៣ កប/វប ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣។

២- វិញ្ញាបនប័ត្រចុះបញ្ជីកាសហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន មីន គួន ចុះបញ្ជីកាលេខ ២៣៧៩ កប/វក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២។

THE ARBITRATION COUNCIL

៣- លិខិតលេខ ០២៣/១២ កប ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន មីន គួន ជាអង្គការវិជ្ជាជីវៈមួយរបស់កម្មករនិយោជិត ដែលបានចុះបញ្ជិកាពេញលក្ខណៈច្បាប់។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន មិន គួន លេខ ៨០៦ កប/អក/វក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន មិន គួន ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៩៧៩ កប/អក/វក/លកអ. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤។

២- លិខិតអញ្ជើញភាគីនិយោជិតចូលរួមសវនាការលេខ ៩៨០ កប/អក/វក/លកអ. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១០១៧ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤។

៤- លិខិតអញ្ជើញភាគីនិយោជិតចូលរួមសវនាការលេខ ១០១៨ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន មិន គួន ថិចថាយ (តទៅនេះ ហៅថា "ក្រុមហ៊ុន មិន គួន") ជាក្រុមហ៊ុនដែលមានសកម្មភាពអាជីវកម្មចម្បង ក្នុងការកាត់ដេរសម្លៀកបំពាក់ ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Inv.៨៥៣E/២០០៤ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤។ ភាគីនិយោជកអះអាងថា បច្ចុប្បន្ន ក្រុមហ៊ុននេះមានជួលកម្មករនិយោជិតចំនួនសរុប ប្រមាណជា ៣៦៧ នាក់។
- នៅក្នុងសំណុំរឿងនេះ សហជីពការងារដើម្បីកម្ពុជា ក្រុមហ៊ុន មីន គួន គឺភាគីដើមបណ្តឹង។
- សហជីពការងារដើម្បីកម្ពុជា ក្រុមហ៊ុន មីន គួន បានទទួលវិញ្ញាបនបត្រចុះបញ្ជិកាសហជីពលេខ ២៣៧៥ ក.ប/វ.ក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២។ សហជីពនេះ បានទទួលវិញ្ញាបនបត្របញ្ជាក់ភាពជាតំណាង

បំផុត លេខ ០៣៣/១៣ ក.ប/វ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ ដែលមានសុពលភាពត្រឹមថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៥។

**ចំណុចវិវាទទី២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់លុយថ្លៃស្នាក់នៅ ឬថ្លៃធ្វើដំណើរចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ**

- ភាគីទាំងពីរបានទទួលស្គាល់ថា ជាការអនុវត្តបច្ចុប្បន្នរបស់ក្រុមហ៊ុន និយោជកបានផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៧ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត។
- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៨ ដុល្លារអាមេរិក ទៅលើប្រាក់បច្ចុប្បន្នចំនួន ០៧ ដុល្លារអាមេរិក សរុបចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - ការចំណាយលើថ្លៃផ្ទះជួល ទឹក និងភ្លើង សុទ្ធតែឡើងថ្លៃ
    - ក្រុមហ៊ុនដែលនៅជុំវិញក្រុមហ៊ុន មិន គួន ជាអាទិ៍ ក្រុមហ៊ុន ខេមបូ ខូថប បានផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរនិងថ្លៃស្នាក់នៅចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត និង ក្រុមហ៊ុន លី ឡាយ បានផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរនិងថ្លៃស្នាក់នៅចំនួន ១២ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត។
    - ថ្លៃផ្ទះជួលបានឡើងថ្លៃពី ៣០ ទៅ ៣៥ ដុល្លារអាមេរិក ក្នុងមួយខែ ចាប់តាំងពីខែធ្នូ ឆ្នាំ២០១៣។
- ភាគីនិយោជកបានឆ្លើយតបថា និយោជកមិនមានលទ្ធភាពផ្តល់ជូនតាមការទាមទាររបស់កម្មករនិយោជិតបានទេ។
- ភាគីកម្មករនិយោជិតបានអះអាងថា បើនិយោជកមិនចំណេញ នោះនិយោជកក៏មិនបង្កើតសាខាច្រើនដែរ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃផុតកំណត់ដាក់ឯកសារនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ដោយភាគីនិយោជក ត្រូវផ្តល់ឯកសារបង្ហាញថា ក្រុមហ៊ុនមិនមានលទ្ធភាពក្នុងការដំឡើងប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ។ រីឯ ភាគីកម្មករនិយោជិត ត្រូវផ្តល់ភស្តុតាងជាវិក័យបត្រប្រចាំខែដែលត្រូវចំណាយលើថ្លៃផ្ទះជួល ទឹក និងភ្លើង ព្រមទាំងភស្តុតាងដែលបង្ហាញថា និយោជកមានលទ្ធភាពក្នុងការដំឡើងប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ។ ភាគីទាំងពីរមិនបានផ្តល់ឯកសារខាងលើជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមកាលកំណត់ទេ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទទី២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៨ ដុល្លារអាមេរិក ពីលើប្រាក់បច្ចុប្បន្នចំនួន ០៧ ដុល្លារអាមេរិក សរុបចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃ

THE ARBITRATION COUNCIL

ស្នាក់នៅចំនួន ០៨ ដុល្លារអាមេរិក ពីលើប្រាក់បច្ចុប្បន្នចំនួន ០៧ ដុល្លារអាមេរិក សរុបចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតដែរ ឬទេ?

ចំណុចទី១ នៃសេចក្តីជូនដំណឹងលេខ ២៣០ កប/ស.ជ.ណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ របស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទាក់ទងនឹងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ សម្រាប់កម្មករនិយោជិតធ្វើការ នៅផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ចែងថា ៖ *"ផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ (ប្រាំពីរ) ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ ។..."*

នៅក្នុងសំណុំរឿងនេះ ការអនុវត្តសព្វថ្ងៃនៅក្នុងក្រុមហ៊ុន គឺនិយោជកផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ ចំនួន ០៧ ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបំពេញកាតព្វកិច្ច ដែលកំណត់ដោយសេចក្តីជូនដំណឹងលេខ ២៣០ កប/ស.ជ.ណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ខាងលើរួចហើយ ។

ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបទប្បញ្ញត្តិច្បាប់ស្តីពីការងារ អនុសញ្ញារួម ឬ កិច្ចព្រមព្រៀងណាមួយរវាងភាគីទាំងពីរ បទបញ្ជាផ្ទៃក្នុង ឬ ការអនុវត្តកន្លងមក ដែលកំណត់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៨ ដុល្លារអាមេរិក ពីលើប្រាក់បច្ចុប្បន្នចំនួន ០៧ ដុល្លារអាមេរិក សរុបចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនេះ គឺជាវិវាទអំពីផលប្រយោជន៍។

ចំពោះវិវាទអំពីផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាដូចខាងក្រោម ៖

កថាខណ្ឌទី២ នៃមាត្រា៩៦ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលទាក់ទងដល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុង មាត្រា៩៦ កថាខណ្ឌទី១ អនុសញ្ញារួមត្រូវធ្វើឡើងដោយព្រមព្រៀងគ្នារវាង ៖*

*ក. មួយចំណែកគឺនិយោជកម្នាក់ និយោជកមួយក្រុម ឬអង្គការមួយ ឬអង្គការច្រើនតំណាងឱ្យនិយោជក" ។*

*ខ. មួយចំណែកទៀត គឺអង្គការសហជីពមួយ ឬអង្គការសហជីពច្រើនតំណាងឱ្យកម្មករនិយោជិត ។... ។"*

លើសពីនេះ ប្រការ៩ នៃប្រកាសលេខ ៣០៥ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ចែងថា ៖ *"សហជីពដែលមានភាពជាតំណាងបំផុត មានសិទ្ធិស្នើសុំឱ្យនិយោជកធ្វើការចរចា អំពីអនុសញ្ញារួម ដែលអនុវត្តចំពោះកម្មករនិយោជិតទាំងអស់ ដែលសហជីពនោះតំណាងឱ្យ។ ក្នុងករណីនេះ និយោជកមានកាតព្វកិច្ចត្រូវតែធ្វើការចរចាជាមួយសហជីព ។"*

យោងតាមមាត្រា ៩៦ នៃច្បាប់ស្តីពីការងារ និងប្រការ ៩ នៃប្រកាសខាងលើ ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណា លើភាពជាតំណាងបំផុតរបស់សហជីព ដែលជាភាគីវិវាទ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពផ្តល់សិទ្ធិតាមផ្លូវច្បាប់ដល់សហជីព ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ ក្នុងការនាំសំណុំរឿងវិវាទ

THE ARBITRATION COUNCIL

អំពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ “*សេចក្តីបង្គាប់អាជ្ញាកណ្តាល ដែលដោះស្រាយវិវាទផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញារួម និងមានប្រសិទ្ធិភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់តាំងពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ*”។

យោងតាមខ្លឹមសារនៃប្រការ ៤៣ នៃប្រកាសខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លើវិវាទអំពីផលប្រយោជន៍ នឹងក្លាយជាអនុសញ្ញារួម ដែលអនុវត្តទៅលើកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតទាំងអស់ បាត់បង់សិទ្ធិក្នុងការធ្វើកូដកម្មដើម្បីទាមទារលើវិវាទ ដែលទាក់ទងនឹងផលប្រយោជន៍ នាពេលអនាគត ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយវិវាទអំពីផលប្រយោជន៍បាន លុះត្រាតែសហជីព ដែលទាមទារនាំយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងបំផុតនៅក្នុងសហគ្រាស ឬសហជីពច្រើនរួមគ្នាទៅ មានចំនួនសមាជិកលើសពីពាក់កណ្តាល នៃកម្មករនិយោជិតនៅក្នុងសហគ្រាស ។ (សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ៨១/០៤-អេវើហ្គ្រីន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤ និងលេខ ៩៨/០៤-ហ្គ្រេតយូនៀន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣)*។

នៅក្នុងសំណុំរឿងនេះ សហជីពការងារដើម្បីកម្ពុជា ក្រុមហ៊ុន មីន គួន ជាភាគីដើមបណ្តឹង ។ សហជីពនេះ បានទទួលវិញ្ញាបនបត្របញ្ជាក់ ភាពជាតំណាងបំផុត លេខ ០៣៧/១៣ ក.ប/វ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ ដែលមានសុពលភាពត្រឹម ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៥ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពនេះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការធ្វើតំណាងឱ្យកម្មករនិយោជិត ដើម្បីនាំយកវិវាទដែលទាក់ទងនឹងផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

ក្នុងករណីដែលសហជីពមានភាពជាតំណាងបំផុត ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាលើវិវាទប្រយោជន៍ ដោយផ្អែកលើគោលការណ៍សមធម៌ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ១១៥/១៤ - តេ យុង ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ និង លេខ ១៥១/១៤ - ធី & ខេ ហ្គាមេន អ៊ិនដាស្រ្ទី*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាយោងតាមគោលការណ៍សមធម៌ថា តើនិយោជកមានកាតព្វកិច្ចក្នុងការបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៨ ដុល្លារអាមេរិក ពីលើប្រាក់បច្ចុប្បន្ន ចំនួន ០៧ ដុល្លារអាមេរិក សរុបចំនួន ១៥ ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិតដែរ ឬទេ?

ការអនុវត្តសព្វថ្ងៃនៅក្នុងក្រុមហ៊ុន និយោជកបានផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៧ ដុល្លារអាមេរិក ក្នុងមួយខែ ។ ផ្ទុយទៅវិញ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៨ដុល្លារអាមេរិក ពីលើប្រាក់បច្ចុប្បន្នចំនួន ០៧ដុល្លារអាមេរិក សរុបចំនួន ១៥ ដុល្លារអាមេរិកក្នុងមួយខែ ។ ភាគីនិយោជកបានលើកឡើងថា និយោជកមិនមានលទ្ធភាពក្នុងការបន្ថែមប្រាក់ សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅនោះទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃផុតកំណត់ដាក់ឯកសារនៅថ្ងៃទី០៨

ខែសីហា ឆ្នាំ២០១៤ ប៉ុន្តែភាគីនិយោជកមិនបានផ្តល់ភស្តុតាងណាមួយ ដើម្បីគាំទ្រថា និយោជកពិតជាមិនមានលទ្ធភាពបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅនោះឡើយ ។

យ៉ាងណាមិញ ភាគីកម្មករនិយោជិតបានធ្វើការទាមទារ ដោយផ្អែកលើហេតុផលថា ការចំណាយលើថ្លៃផ្ទះជួល ទឹក និងភ្លើង សុទ្ធតែឡើងថ្លៃ។ នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ក្រុមហ៊ុនផ្សេងក្បែរៗនោះមានដូចជា ក្រុមហ៊ុន ខេមបូ ខូថប បានផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ និងក្រុមហ៊ុន លី ឡាយ បានផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ១២ ដុល្លារអាមេរិកក្នុងមួយខែ។ លើសពីនេះ ភាគីកម្មករនិយោជិតបានជំទាស់ថា ក្រុមហ៊ុនចំណេញច្រើន ដោយសារក្រុមហ៊ុននេះមានបង្កើតសាខាថ្មី។ ភាគីកម្មករនិយោជិត មិនបានបង្ហាញភស្តុតាងវិក័យបត្រប្រចាំខែ ដែលត្រូវចំណាយលើថ្លៃផ្ទះជួល ទឹក និងភ្លើង ដើម្បីគាំទ្រការទាមទារបន្ថែមប្រាក់ សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗយល់ឃើញថា ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់គឺមាន បន្ទុកភស្តុតាង។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ៧៥/០៥-អេវើហ្គ្រីន, លេខ ១០១/០៨-ជីឌីអឹម ហេតុផលចំណុចវិវាទទី១ និងទី២, លេខ ១៦៨/០៩-ទីកថ្លា ផ្លាហ្សា ហេតុផលចំណុចវិវាទទី២ និង លេខ ១១៥/១០-ជី-ហ្វូម៉ូស ហេតុផលចំណុចវិវាទទី១៨ និង១៤៨/១១-ដាយ យ៉ាំង*)។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការទាមទារមិនមានភស្តុតាងជាក់លាក់ ដើម្បីសម្អាងលើការទាមទារនោះទេ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ៦៣/០៤-សាញ វែល ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤, លេខ ៩៥/០៦-សៅធ៍ បាយ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤, លេខ ៥១/០៧-ហ្គោលហ្វេម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ និង លេខ ២៤/១៤ - កាឡាខេម អ៊ិនវេសមេន*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ឃើញដូចក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនៗខាងលើដែរ។ ហេតុនេះ ដោយភាគីកម្មករនិយោជិតមិនបានបំពេញបន្ទុកភស្តុតាង ក្នុងការទាមទារក្នុងសំណុំរឿងនេះ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៨ ដុល្លារអាមេរិក ពីលើប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅបច្ចុប្បន្នចំនួន ០៧ ដុល្លារអាមេរិក សរុបចំនួន ១៥ ដុល្លារ អាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៨ ដុល្លារអាមេរិក ពីលើប្រាក់បច្ចុប្បន្នចំនួន ០៧ ដុល្លារអាមេរិកក្នុងមួយខែ សរុបចំនួន ១៥ ដុល្លារ អាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិត។

THE ARBITRATION COUNCIL

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និង ថ្លៃស្នាក់នៅចំនួន ០៨ ដុល្លារអាមេរិក ពីលើប្រាក់បច្ចុប្បន្នចំនួន ០៧ ដុល្លារអាមេរិកក្នុងមួយខែ សរុបចំនួន ១៥ ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិត ។

**ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **សេង ឡូចហ៊ុន**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **លឹម សុវណ្ណា**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល

ឈ្មោះ ៖ **អាំង អេង ថុង**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL